# ហូលពិតានខ្មែរ៖ សិល្បៈតម្បាញជាប់នឹងជំនឿ

ក្នុងចំណោមសិល្បៈត្បាញរវៃដ៏សម្បូរបែបនៅកម្ពុជា ហូលពិតានជាសំពត់ត្បាញពីសូត្រ រំលេចសាច់រឿងពុទ្ធប្រវត្តិ ឬរឿងជាតកផ្សេងៗ សម្រាប់ប្រើជាសក្ការៈតាមទំនៀមនិងជំនឿ ពោលគឺហូលពិតានពុំសម្រាប់ស្លៀកដណ្តប់ដូចសំពត់ធម្មតាឡើយ។ ក្នុងក្រសែភ្នែកអ្នកស្រាវជ្រាវ តម្បាញហូលពិតាន ពុំត្រឹមតែបង្ហាញពីទេពកោសល្យដ៏ប៉ិនប្រសប់នៃបច្ចេកទេសត្បាញសរសៃសូត្រប៉ុណ្ណោះទេ តែហូលពិតានបានឆ្លុះបញ្ចាំងពីចំណេះ និងជំនឿតាំងដូនតាមកៗ សោតឯវិជ្ជាក្នុងកិច្ចការត្បាញហូលពិតាននេះ ភាគច្រើនកើតពីការរៀនសូត្របន្តគ្នាក្នុងគ្រួសារ ឬក្នុងភូមិ ពីជំនាន់មួយទៅជំនាន់មួយ។ ប៉ុន្តែសព្វថ្ងៃនៅតាមភូមិពុំសូវមានអ្នកចេះត្បាញហូលពិតានឡើយ ហើយទំនៀមសាងហូលពិតានបូជាព្រះតាមវត្ត (រូបលេខ១) ឬប្រើហូលពិតានក្នុងកិច្ចប្រពៃណីក៏ហោចទៅ។



រូបលេខ១ ហូលពិតាននៅវត្តអង្គអណ្តែត ក្នុងខេត្តតាកែវ (រូបថត៖ B. Dupaigne)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដូចបានលើកឡើងខាងដើមថា ហូលពិតានមានលក្ខណៈពិសេសជាងហូលធម្មតា ដ្បិតហូលនេះមានលើកគោមជារូបផ្សេងៗដែលទាក់ទងនឹងជំនឿសាសនា។ ហូលពិតានមានឈ្មោះផ្សេងៗអាស្រ័យលើរូបនៅលើហូលពិតាន និងការហៅតាមតំបន់ដូចជា ពិតានរូបព្រះ ពិតានរូបប្រាសាទ ពិតានរូបទង់ ឬពិតានរូបទូក ។ល។ ជាទូទៅ ហូលពិតានប្រើសម្រាប់ចងជាពិតាន លើព្រះដីរ៍ក្នុងព្រះវិហារ សាលាឆាន់ ឬប្រើក្នុងពិធីបុណ្យ។ ដូច្នេះដោយហេតុថា ហូលពិតានមានលើកគោមជារឿង និងមានក្បាច់ពិសិដ្ឋ អ្នកស្រុកមានតំណមមិនឲ្យយកហូលពិតានមកប្រើ ឬស្លៀកដូចហូលធម្មតាទេ។ មិនតែប៉ុណ្ណោះ គោមដែលប្រើនៅលើហូលពិតានខ្លះ ក៏មិនត្រូវយកមកត្បាញលើហូលសម្រាប់ស្លៀកដែរ។ គោមទាំងនោះរួមមាន រូបព្រះ រូបវិហារ រូបទង់ រូបហង្ស រូបទូក និងរូបផ្កាបិណ្ឌជាដើម (រូបលេខ២)។[1]



រូបលេខ២ មួយផ្នែកនៃហូលពិតានត្បាញរឿងមហាវេស្សន្តរជាតក

[1] ស៊ីយ៉ុន សុភារិទ្ធ, ២០០៨: ២០-២១

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ជាការពិត អ្វីដែលធ្វើឱ្យហូលពិតានមានតម្លៃមិនអាចកាត់ថ្លៃបាន គឺការចងក្បៀតលើកគោម និងក្បាច់រចនាស្មុគស្មាញខុសពីហូលសម្រាប់ស្លៀក ដែលច្រើនតែមានគោមក្បាច់ភ្ញីផ្កាតូចៗដដែលៗបន្តគ្នា។ ហេតុដូច្នេះ គេស្ទើរតែអាចប្រៀបធៀបហូលពិតានដូចជាគំនូរលើផ្ទៃសំពត់សូត្រ។ អ្នកត្បាញហូលនេះច្រើនជាមនុស្សចាស់ មានពិសោធក្នុងការត្បាញ មានចិត្តអំណត់ព្យាយាម ហើយចេះនិងយល់សាច់រឿងផ្សេងៗក្នុងសាសនា ឬទេវកថាផង (រូបលេខ២៣-៤)។ ជាទូទៅអន្ទើសាច់រឿងដែលគេតែងលើកគោមត្បាញក្នុងពុទ្ធប្រវត្តិមានដូចជា ទ្រង់ប្រសូត្រ ត្រាស់ដឹង និងបរិនិព្វាន។ ចំណែកឯអន្ទើសាច់រឿងក្នុងមហាវេស្សន្តរជាតកច្រើនតែត្បាញបង្ហាញនូវគ្រង់ការបំពេញទានបារមីរបស់ព្រះវេស្សន្តរ ដាក់ទានដំរី ដាក់ទានរាជរថ ដាក់ទានជាលីនិងក្រឹស្នាជាដើម។ ដោយឡែកចំពោះការត្បាញរូបផ្សេងៗមានដូចជា រូបសត្វហង្ស នាគ ដំរី ឬរូបទេវតា ដែលច្រើនតែនិទានក្នុងរឿងទេវកថា (រូបលេខ២៥-៨)។



រូបលេខ២៣-៤ ស្ត្រីចំណាស់ដែលមានចំណេះត្បាញហូលពិតាន



រូបលេខ២៥-៨ គំរូគោមរូបសត្វ និងរូបផ្សេងៗត្បាញលើហូលពិតាន

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ប្រសិនបើនិយាយពីដំណាក់កាល បច្ចេកទេស និងកិច្ចការពាក់ព័ន្ធខ្លះ ទម្រាំកើតបានជាហូលពិតាន គឺមានច្រើន និងស្មុគស្មាញ ហើយផ្នែកខ្លះមនុស្សទូទៅពិបាកយល់ផង។ បើរាប់ត្រឹមយកសរសៃសូត្រមកចងគាត គឺគេត្រូវរកមនុស្សណាដែលយល់សាច់រឿងគូសវាសលើកគោមច្បាស់លាស់ ជាពិសេសសាច់រឿងក្នុងពុទ្ធប្រវត្តិ ឬរឿងក្នុងជាតក ដោយពឹងផ្អែកលើគំរូគោមចាស់ដូចមានបង្ហាញខាងលើ ឬមើលគំនូរតាមវត្ត។[2] ទន្ទឹមនោះដែរ គេអាចបន្ថែមបន្ថយចំណុចខ្លះទៀតតាមគំនិតទេពកោសល្យសិល្បៈច្នៃប្រតិដ្ឋ តាមការចង់បាន។ រូបខាងក្រោម ជាឧទាហរណ៍បង្ហាញការរៀបចំលើកគោមចងគាតរឿងក្នុងពុទ្ធប្រវត្តិ (រូបលេខ៩) និងការប្រៀបធៀបចំណុចមួយផ្នែកនៃហូលពិតានត្រង់ព្រះពុទ្ធផ្ចាញ់មារទៅនឹងគំនូរតាមវត្ត (រូបលេខ១០-១១)។



រូបលេខ៩-១១ ឧទាហរណ៍នៃការរៀបចំចងគាត និងការប្រៀបធៀបរូបលើហូលពិតានជាមួយគំនូរ

ក្រៅពីការឈ្លាសវៃនិងមានទេពកោសល្យសិល្បៈប្រិតប្រៀងចងគាតឲ្យកើតជារូបផ្សេងៗហើយ គេត្រូវយល់ពីប្រភេទពណ៌ដែលសមរម្យល្អ និងត្រូវប្រើលើផ្នែកនីមួយៗនៃរូបនោះដែរ ជាពិសេសគឺពណ៌ធម្មជាតិ។ ពណ៌ក្រហម បានពីល័ក្តក្រម៉ (ឬហៅល័ក្តខ្មែរ) គ្រាប់ដំពូ ឬដើមស្បែង។ ពណ៌លឿង បានពីសំបកដើមព្រហូត រមៀត ឬខ្ចីមខ្នុរ។ ពណ៌ខ្មៅ បានពីផ្លែមក្លឿ (ឬហៅផ្លែខ្លួញ) និងពណ៌ខៀវ បានពីរុក្ខជាតិត្រុំ ដែលគេធ្វើជាធ្នះ ដើម្បីឲ្យ

[2] សូមអានបន្ថែម៖ សោ ចន្ថា, ២០១៥: ៣២

កើតជាដុំមរ។ ពណ៌ទាំងអស់នេះ ត្រូវយកទៅជ្រក់សរសៃសូត្រដែលចងគាតរួច ទៅតាមដំណាក់កាលនិងបច្ចេកទេសផ្សេងៗគ្នា។[3]



រូបលេខ១២ ហូលពិតានដែលមានរូបផ្សេងៗដាក់បង្ហាញក្នុងពិព័រណ៌សិប្បកម្មខ្មែរ

បច្ចុប្បន្ន ហូលពិតានបានក្លាយជាវត្ថុសិល្បៈកម្រ ប្រឈមការថមថយនៃការត្បាញ និងប្រើប្រាស់តាមរបៀបបុរាណ។ កន្លងនេះ គេមើលឃើញទៅលើភាពស្មុគស្មាញនៃការចងគាត ការត្បាញ និងតម្លៃ។ ប៉ុន្តែសិប្បករនៅតាមតំបន់មួយចំនួនដូចជា ខេត្តតាកែវ និង

[3] ស សុខនី, ផាត់ ចន្ទមុនីរដ្ឋា, សោម វណ្ណៈ, ២០០៧

សៀមរាប នៅតែបន្តត្បាញហូលពិតានខ្លះ ដើម្បីកុំឱ្យមត៌កដូនតាមួយនេះរលាយបាត់។ ទន្ទឹមនោះ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក៏តែងរៀបចំពិព័រណ៍ជារឿយៗពាក់ព័ន្ធនឹងហូលពិតានផងដែរ។ បើរាប់តែក្នុងសារមន្ទីរជាតិភ្នំពេញ ពិព័រណ៍ហូលពិតានធ្លាប់រៀបចំឡើងនៅឆ្នាំ២០១០ ឆ្នាំ២០១២ ឆ្នាំ២០១៦ និងចុងក្រោយនៅឆ្នាំ២០២៤ ដែលមានវត្តមានកិត្តិយសរបស់ **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** អញ្ជើញទស្សនាផ្ទាល់ (រូបលេខ១៣-១៤)។ ទន្ទឹមនោះ គេដឹងថានៅសារមន្ទីរវាយភ័ណ្ឌអាស៊ីក្នុងខេត្តសៀមរាប ក៏ធ្លាប់ដាក់តាំងហូលពិតាន និងទទួលអំណោយហូលពិតាន ពីសប្បុរសជនជាបន្តបន្ទាប់ ដើម្បីថែរក្សា និងអភិរក្សដូចនៅសារមន្ទីរជាតិភ្នំពេញដែរ។



រូបលេខ១៣-១៤ លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត អញ្ជើញទស្សនាស្វែងយល់អំពីហូលពិតានកាលតាំងបង្ហាញក្នុងសារមន្ទីរជាតិ ឆ្នាំ២០២៤ (ប្រភព៖ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ)

អរិយធម៌ខ្មែរ KHMER CIVILIZATION

ជារួមមក ហូលពិតានពុំត្រឹមតែជាផលិតផលកើតពីសរសៃសូត្រដូចហូលស្លៀកធម្មតាទេ តែហូលពិតានជា "សិល្បៈសក្ការៈ" ដែលបានត្បាញយ៉ាងផ្ចិតផ្ចង់ភ្ជាប់នូវជំនឿសាសនា សីលធម៌ និងអត្តសញ្ញាណវប្បធម៌។ ទោះបីជាបច្ចុប្បន្ន វត្តមានហូលពិតានហាក់មានការថមថយតាមវត្តអារាមមួយចំនួន ប៉ុន្តែការចាប់ផ្តើមយកចិត្តទុកដាក់ឡើងវិញតាមរយៈការតាំងពិព័រណ៍ ការស្រាវជ្រាវ និងការគាំទ្រពីថ្នាក់ដឹកនាំ ក៏ដូចជាស្ថាប័នពាក់ព័ន្ធ គឺជាសញ្ញាវិជ្ជមានក្នុងការជួយស្រោចស្រង់មត៌កដ៏កម្រនេះ៕

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ស សុខនី, ផាត់ ចន្ទមុនីរដ្ឋា, សោម វណ្ណៈ

២០០៧, *បច្ចេកទេសជ្រលក់ពណ៌ធម្មជាតិ និងគម្រូផលិតកម្មតម្បាញសូត្រប្រពៃណីខ្មែរ*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ស៊ីយ៉ុន សុភារិទ្ធ

២០០៨, *ពិតាននៅក្នុងជំនឿនិងកិច្ចប្រតិបត្តិ*, រៃឃំ, ភ្នំពេញ

សោ ចន្ទា

២០១៥, *តម្បាញសូត្រនិងការប្រឈមនាពេលបច្ចុប្បន្ន (ភូមិកញ្ចាង ឃុំស្វា ស្រុកសំរោង ខេត្តតាកែវ)*, សារណាបញ្ចប់បរិញ្ញាបត្រមហាវិទ្យាល័យបុរាណវិទ្យា, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ